Weekly Bulletin (Week2) June, 2010

ព្រឹត្តិបត្រ ព័ត៌មានប្រចាំសប្តាហ៍
កសិកម្ម និងអភិវឌ្ឍន៍ជនបទ

## ៣ខែដើមឆ្នាំថៃនាំទំនិញចូល៧០០លានដុល្លារ

*(អេវីរីដេ ១៤ មិថុនា ២០១០)*

លោកភួនស័ក្តិគុណឧត្តមទីប្រឹក្សាពាណិជ្ជកម្មប្រចាំស្ថានទូតថៃនៅកម្ពុជាបានថ្លែងថារយៈពេល៣ខែដើម ឆ្នាំ ២០១០នេះថៃបាននាំទំនិញចូលទីផ្សារ កម្ពុជាមានទឹកប្រាក់ប្រមាណជា ៧០០លានដុល្លារហើយកម្ពុជាបាននាំទំនិញចូលទីផ្សារថៃប្រមាណជា ២៤ លានដុល្លារអាមេរិក។ លោកភួនស័ក្តិគុណឧត្តមបានថ្លែងបែបនេះនៅក្នុងសន្និសីទកាសែតមួយកាលពីថ្ងៃទី ១១មិថុនានៅសណ្ឋាគារភ្នំពេញស្តីពីការតាំងពិព័រណ៍ពាណិជ្ជកម្មថៃ ២០១០។ លោក ស្រីជីវ៉ាណាន់វង្សមង្គលអគ្គទីប្រឹក្សាពាណិជ្ជកម្មប្រចាំស្ថានទូតថៃនៅកម្ពុជាបានថ្លែងថាក្រសួងពាណិជ្ជកម្មថៃ និងក្រសួងពាណិជ្ជកម្មកម្ពុជានឹងធ្វើជាសហប្រធានក្នុងការរៀបចំ"ពិពរណ៍ពាណិជ្ជកម្មថៃ ២០១០"នៅប្រទេសកម្ពុជា។ ពិព័រណ៍ពាណិជ្ជកម្មនេះនឹងរៀបចំធ្វើចាប់ពីថ្ងៃទី ១៧ដល់ថ្ងៃទី ២០ មិថុនាឆ្នាំ ២០១០ពីម៉ោង ៩ព្រឹកដល់ម៉ោង៩យប់នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្ររាជធានីភ្នំពេញ។ ក្រុមហ៊ុនទាំងនេះនឹងធ្វើការដាក់បង្ហាញនិងលក់ទំនិញជាច្រើនប្រភេទដូចជាទំនិញម្ហូបអាហារនិងភេសជ្ជៈផលិតផលធ្វើអំពីស្បែកសំភារៈសិក្សានិងគ្រឿងសំអាង។

## ផ្លាស់មេព្រៃ៣ខេត្តក្នុងយុទ្ធនាការដៃដែក

*(អេវីរីដេ ១៤ មិថុនា ២០១០)*

ប្រភពគួរឱ្យទុកចិត្តមួយបាននិយាយថាមាននាយខណ្ឌរដ្ឋបាលព្រៃឈើចំនួន៣ខេត្តនឹងត្រូវផ្លាស់ប្តូរនៅពេលឆាប់ៗខាងមុខនេះ ដើម្បីកែទម្រង់និងដើម្បី ប្រសិទ្ធភាពការងារចាំបាច់របស់ក្រសួង កសិកម្មរុក្ខាប្រមាញ់ និងនេសាទក៏ដូចជាការ បំបាត់ភាពអនាធិបតេយ្យព្រៃឈើផងដែរ។ព័ត៌មានពីក្រុមមន្ត្រីបាននិយាយថានាយខណ្ឌរដ្ឋបាលព្រៃឈើដែលផ្លាស់ប្តូរថ្មីចំនួន ៣ខេត្តនោះមានខេត្តសៀមរាបខេត្តបន្ទាយមានជ័យនិងខេត្តឧត្តរមានជ័យ។ ក្រុមមន្ត្រី បានបញ្ជាក់ទៀត ថាការផ្លាស់ប្តូរប្រធានខណ្ឌរដ្ឋបាលព្រៃឈើថ្មីខាងលើគឺធ្វើឡើងដើម្បីប្រសិទ្ធភាពការងារ ចាំបាច់មួយរបស់ក្រសួង កសិកម្មរុក្ខាប្រមាញ់និងនេសាទ ក៏ដូចជារាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង វិស័យព្រៃឈើ ឱ្យមានប្រសិទ្ធភាពខ្ពស់ជាងបច្ចុប្បន្ន។ក្រុម មន្ត្រីដដែលបានបញ្ជាក់ទៀតថាការផ្លាស់ប្តូរថ្នាក់ដឹកនាំបណ្តា រដ្ឋបាលព្រៃឈើខេត្ត ទាំងបីបើពុំមានការប្រែប្រួលទេថ្នាក់លើនឹងធ្វើពិធីប្រកាសជាផ្លូវការនៅពេលឆាប់ៗ ខាងមុខនេះ។

## គម្រោងជីកអណ្តូងចំនួន ១០០០កន្លែងនៅទូទាំងប្រទេស

*(វិទ្យុអូស្ត្រាលី ១៣ មិថុនា ២០១០)*

រដ្ឋាភិបាលបានកំពុងធ្វើការជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិដើម្បីកុមារ និងអង្គការរូបិយវត្ថុពិភពលោកដើម្បីដោះស្រាយបញ្ហាកង្វះទឹកខាតទឹកស្អាត។ រដ្ឋាភិបាលបានផ្តល់ទឹកប្រាក់ប្រមាណ ៩សែនដុល្លារអាមេរិកសម្រាប់គម្រោងជីកអណ្តូងទឹកចំនួន ១០០០អណ្តូងសម្រាប់ប្រជាកសិករនៅតំបន់ដាច់ស្រយាលទូទាំង ២៤ខេត្តក្រុង ដើម្បីឱ្យពួកគាត់មានទឹកស្អាតប្រើប្រាស់។

## ភាគច្រើននារីស្ថិតក្នុងវ័យ ១៨ឆ្នាំស្វែងរកសេវារំលូតកូន

*(ដើមអំពិល ១២ មិថុនា ២០១០)*

លោកស្រីវិជ្ជបណ្ឌិតជូ ពិន បុគ្គលិកមន្ទីរពេទ្យកាល់ម៉ែត្រផ្នែកសម្ភព និងរោគស្ត្រីមានប្រសាសន៍ថា ស្ត្រីភាគច្រើនដែលរកសេវារំលូតកូនភាគច្រើនគឺមានអាយុ ១៨ឆ្នាំ ដែលលោកស្រីបញ្ជាក់ថា ការរំលូតកូនក្នុងវ័យក្មេងនេះ គឺអាចប្រឈមទៅហ្នឹងភាពគ្មានកូនជារៀងរហូត និងអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ជីវិត។

## ផ្តល់ថវិកា ២.២លានដុល្លារដល់ក្រសួងផែនការកម្ពុជា

*(វិទ្យុអាស៊ីសេរី ១១ មិថុនា ២០១០)*

អង្គការ JICA របស់ប្រទេសជប៉ុន បានផ្តល់ទឹកប្រាក់ចំនួន ២.២លានដុល្លារអាមេរិកដល់ក្រសួងផែនការកម្ពុជា ដែលជាជំនួយឥតសំណងសម្រាប់ធ្វើជំរឿនសហគ្រាសតាមខេត្តក្រុងនៅកម្ពុជាពីឆ្នាំ ២០១០ ដល់ ២០១៥ រយៈពេល ៥ឆ្នាំ។

## គម្រោងអភិរក្សព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប

*(វិទ្យុអូស្ត្រាលី ១១ មិថុនា ២០១០)*

រដ្ឋាភិបាលកម្ពុជាកំពុងមានគម្រោងប្រកាសចាត់ទុកព្រៃលិចទឹកជាង ៦សែនហិកតានៅជុំវិញបឹងទន្លេសាបថាជាតំបន់អភិរក្ស។ គម្រោងនេះ ធ្វើឡើងក្នុងគោលបំណងបញ្ឈប់ការកាប់បំផ្លាញព្រៃឈើលក្ខណៈទ្រង់ទ្រាយធំ ដែលជាជម្រកដ៏សំខាន់នារដូវវស្សាសម្រាប់ត្រីដែលរស់នៅក្នុងបឹងទន្លេសាបនេះ។ មានម្តងនោះ តំបន់អភិរក្សនេះពង្រីកដល់ទៅ ១លានហិកតា ប៉ុន្តែការធ្វើកសិកម្មសម្រាប់ធ្វើជំនួញទ្រង់ទ្រាយធំ ព្រមទាំងភ្លើងឆេះព្រៃកាលពីរដូវក្តៅបានធ្វើឱ្យអន្តរាយដល់ព្រៃលិចទឹកនេះឱ្យនៅរួមតូចជាងមុន។

## ចិននឹងបើកសាខាធនាគារមួយនៅកម្ពុជា

*(អេវីរីដេ ១១ មិថុនា ២០១០)*

ធនាគារចិនដែលមានទុនវិនិយោគរាប់ពាន់លានដុល្លារនឹងបើកសាខារបស់ខ្លួននៅក្នុងប្រទេសកម្ពុជានៅក្នុងពេលខាងមុខ។ នេះបើតាមការអះអាងរបស់មន្ត្រីធនាគារជាតិកម្ពុជាបានឱ្យដឹងក្រោយពេលដែលលោក ជា ចាន់តូអគ្គទេសាភិបាលធនាគារជាតិកម្ពុជាជួបជាមួយឯកអគ្គរដ្ឋទូតចិនថ្មីប្រចាំនៅកម្ពុជា។ មន្ត្រីដដែលនោះបានអះអាងថាធនាគារជាតិនៃកម្ពុជាបានយល់ព្រមជាគោល

ការណ៍ឱ្យធនាគារចិនបើកសាខានៅក្នុងទីក្រុងភ្នំពេញរួចរាល់ហើយ។ គេនៅមិនទាន់ដឹងថាធនាគារចិននេះនឹងបើកសាខារបស់ខ្លួននៅក្នុងទីក្រុងភ្នំពេញនៅពេលណាហើយមានទឹកប្រាក់ប៉ុន្មាននោះទេប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តាមច្បាប់របស់ធនាគារកាលណាធនាគារជាតិយល់ព្រមជាគោលការណ៍ឱ្យធនាគារណាមួយបើកនៅក្នុងប្រទេសកម្ពុជាហើយនោះធនាគារនោះមានរយៈពេល៦ខែដើម្បីបំពេញបែបបទនិងរៀបចំទីតាំងឱ្យបាន។ យោងតាមវេបសាយរបស់ធនាគារចិននេះបានឱ្យដឹងថា រហូតមកដល់ពេលនេះធនាគារនេះគឺជាធនាគារដ៏ធំមួយនៅក្នុងប្រទេសចិនដែលមានទុនទាំងអស់ប្រមាណជា ១៤០០ពាន់លានដុល្លារ។ មន្ត្រីខាងលើនេះបានឱ្យដឹងថាធនាគារនេះគឺជាធនាគារចិនទីមួយហើយដែលនឹងបើកសាខានៅក្នុងប្រទេសកម្ពុជា។

## ឆ្នាំនេះខ្យល់ព្យុះកើតច្រើនជាងឆ្នាំមុន

*(អេរីវីរដេ ១១ មិថុនា ២០១០)*

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយកាលពីថ្ងៃព្រហស្បតិ៍បានឱ្យដឹងថានៅដើមឆ្នាំ ២០១០ ករណីខ្យល់ព្យុះមានការកើនឡើងដល់ទៅ ១៣លើកបើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ យោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដែលភ្នំពេញប៉ុស្តិ៍ទទួលបានកាលពីថ្ងៃព្រហស្បតិ៍បានឱ្យដឹងថាក្នុងរយៈពេល៥ខែដើមឆ្នាំ ២០១០ គ្រោះមហន្តរាយដោយ សារខ្យល់ព្យុះបានកើតឡើងដល់ទៅ ៦២ករណីក្នុងនោះបានធ្វើឱ្យខូចខាតទ្រព្យសម្បត្តិប្រជាពលរដ្ឋជាច្រើនដូចជាដួលរលំផ្ទះចំនួន ៤៥៦ខ្នងប៉ើងដំបូលនិងជញ្ជាំងចំនួន១៩០៧ខ្នងនិងរបើកដំបូលសាលារៀន ២៣ខ្នងស្លាប់ដោយសាររន្ទះបាញ់ ១៧នាក់របួស៣៨នាក់និងងាប់គោចំនួន១១ក្បាលផងដែរ។ គ្រោះមហន្តរាយនេះបើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០០៩វាមានការកើនឡើងដល់ទៅ១៣លើក។លោកកែវវីអនុប្រធាននាយកដ្ឋានព័ត៌មាននិងទំនាក់ទំនងនៃ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានប្រាប់ភ្នំពេញប៉ុស្តិ៍ថាករណីខ្យល់ព្យុះនៅក្នុងឆ្នាំ ២០១០មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងឆ្នាំ២០០៩ដែរប៉ុន្តែការខូចខាតវាមានកម្រិតធ្ងន់ធ្ងរជាង។លោកថ្លែងថាមូលហេតុដែលបណ្តាលឱ្យមាន ករណីនេះកើនឡើងគឺបណ្តាលមកពីឆ្នាំនេះ ភ្លៀងកក់ខែច្រើនតាំងពីដើមឆ្នាំដែលវាមានការខុសប្លែកពីឆ្នាំមុន។

## ពលរដ្ឋ ១២៨គ្រួសារបានទទួលដីសម្បទានសង្គមកិច្ច

*(ដើមអំពិល ១០ មិថុនា ២០១០)*

ប្រជាពលរដ្ឋក្រីក្រ ១២៨គ្រួសារ ដែលពីមុនរស់នៅលើដីសាធារណៈបានទទួលដីសម្បទានសង្គមកិច្ចដោយរៀបចំប្រគល់ពីអាជ្ញាធរខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១០។ ទីតាំងចែកដីស្ថិតនៅភូមិនាងគង្ហីង សង្កាត់សំបូរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

## កសិផលសណ្តែកកម្ពុជាមានតម្លៃថ្លៃខណៈពេលតម្រូវការទីផ្សារខ្ពស់

*(វិទ្យុអូស្ត្រាលី ០៩ មិថុនា ២០១០)*

តម្លៃសណ្តែកនៅក្នុងរដូវប្រមូលផលឆ្នាំនេះនៅខេត្តបាត់ដំបងបានកើនឡើងគួរសម ខណៈពេលដែលឈ្មួញវៀតណាម និងថៃទទួលទិញដើម្បីនាំចេញ។ បើតាមរបាយការណ៍សរុបប្រចាំឆ្នាំ២០០៩ នៅខេត្តបាត់ដំបងមានដាំដំណាំពោតជាង ១២ម៉ឺនហិកតា សណ្តែកបាយជាង ១៣ពាន់ហិកតា សណ្តែកសៀងជិត ៥ម៉ឺនហិកតា និងល្ងជាង ១១ពាន់ហិកតា។

## ធនាគារទិញប្រាក់រៀលឱ្យតម្លៃដើបវិញ

*(អេវ៉ីរ៉េដេ ០៩ មិថុនា ២០១០)*

ធនាគារជាតិបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយកាលពីម្សិលមិញថាខ្លួនកំពុងទិញលុយរៀលដែលមានតម្លៃ ៣លានដុល្លារទៀតនៅសប្តាហ៍នេះដើម្បីជួយឱ្យរូបិយប័ណ្ណជាតិមានតម្លៃទល់នឹងប្រាក់ដុល្លារ វិញដោយធ្វើឱ្យចំនួនប្រាក់ដុល្លារសរុបនៃការទិញកើនឡើង ១០លានដុល្លារហើយ ។ធនាគារកណ្តាលនេះកំពុងព្យាយាមយកដុល្លារដូរយកលុយរៀល ដើម្បីធ្វើឱ្យរូបិយប័ណ្ណក្នុងស្រុកកាន់តែក្រខ្សត់ដើម្បីវាកាន់តែមានតម្លៃ។ យោងតាមសេចក្តីថ្លែងការណ៍របស់ធនាគារពាណិជ្ជកម្មនានានៅថ្ងៃនេះនិងថ្ងៃសុក្រនឹងមានការទិញចំនួន២លានដុល្លារ។ យោងតាមហាងប្តូរប្រាក់លីហួរ ដែលជាហាងប្តូរប្រាក់ធំជាងគេក្នុងរាជធានីភ្នំពេញ បានឱ្យដឹងថាអត្រាប្តូរប្រាក់រៀលគឺ ៤.២៦២រៀល ក្នុង១ដុល្លារកាល ពីរសៀលម្សិលមិញ គឺទទួលបាន ០,២៥ ភាគរយបើប្រៀបធៀបទៅនឹងថ្ងៃដូចគ្នាកាលពីសប្តាហ៍មុននិងជាសញ្ញាមួយបង្ហាញថា ការទិញប្រាក់រៀលរបស់ធនាគារកំពុងចាប់ផ្តើមមានឥទ្ធិពលខ្លះហើយ។ ទោះជាយ៉ាងណាតម្លៃប្រាក់រៀលបើប្រៀបធៀប នឹងប្រាក់ដុល្លារនៅតែធ្លាក់ចុះ ៣,៤៤ភាគរយបើប្រៀបធៀបនឹងអត្រាប្តូរប្រាក់កាល ពីខែមេសាដែលនៅពេលនោះវាមានតម្លៃ ៤.១២០រៀលក្នុង១ដុល្លារ។

## កម្ពុជាធ្លាក់ចំណាត់ថ្នាក់សន្តិភាពពិភពលោក

*(អេវ៉ីរ៉េដេ ០៩ មិថុនា ២០១០)*

ប្រទេសកម្ពុជាស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ១១១ក្នុងចំណោមប្រទេសទាំង ១៤៩នៅក្នុងសន្ទស្សន៍សន្តិភាពពិភពលោកដែលបានចេញផ្សាយកាលពីថ្ងៃអង្គារគឺបានធ្លាក់ចុះ៦លេខបើធៀបនឹងឆ្នាំ២០០៩។ នៅក្នុងសេចក្តីថ្លែងការណ៍មួយដែលចេញផ្សាយដោយក្រុមហ៊ុន Hill and Knowlton ក្រុមហ៊ុនស្រាវជ្រាវនៅប្រទេសអង់គ្លេសដែលបានធ្វើរបាយការណ៍នេះឱ្យវិទ្យាស្ថានសម្រាប់កិច្ចការ សេដ្ឋកិច្ចនិងសន្តិភាពបានឱ្យដឹងថាប្រទេសកម្ពុជាបានធ្លាក់ចំណាត់ថ្នាក់ក្នុងឆ្នាំ ២០១០ដោយផ្អែកទៅតាមអត្រាមនុស្សឃាតនិងការចំណាយផ្នែកយោធាកើនឡើង។ សន្ទស្សន៍នេះបានផ្តល់ពិន្ទុពី១ដល់៥ក្នុងសូចនាករកំណត់ទាំង ២៣រួមមានទាំងអត្រាឧក្រិដ្ឋកម្មនៅក្នុងសង្គម ការប្រើប្រាស់អាវុធយុទ្ធភណ្ឌ អនាធិបតេយ្យនិងចំនួនកើតមានជម្លោះច្រើន។ ប្រទេសកម្ពុជាមានពិន្ទុមធ្យម២,២៥២ពិន្ទុ។ ផ្ទុយមកវិញ ប្រទេសញូហ្ស៊ីលែនមានចំណាត់ ថ្នាក់ខ្ពស់ជាងគេក្នុងរយៈពេល២ឆ្នាំជាប់ៗគ្នាដែលទទួលបានពិន្ទុមធ្យម១,២០២។

## អ្នកជំនាញ៖ សេដ្ឋកិច្ចកម្ពុជាកើនឡើងប្រមាណ ៥%ក្នុងឆ្នាំ២០១០

*(វិទ្យុអាស៊ីសេរី ០៨ មិថុនា ២០១០)*

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា លោកហង់ ជួនណារ៉ុន មានប្រសាសន៍ថា សេដ្ឋកិច្ចកម្ពុជាបានកើនឡើងប្រមាណ ៥% ក្នុងរយៈពេល ៣ខែដើមឆ្នាំដូចគ្នា ប្រៀបធៀបនឹងឆ្នាំ ២០០៩ ហើយបញ្ហាអតិផរណាដែលមានន័យថាទំនិញឡើងថ្លៃ និងប្រាក់ចុះថោកវិញ ក៏បានធ្លាក់ចុះ បើប្រៀបធៀបនឹងខែ ៤ឆ្នាំ ២០០៩ គឺមានប្រមាណ ៥.៣% ។

## ចំណូលគយខែមុនបានជិត៥៩លានដុល្លារ

*(អេវីរីដេ ០៨ មិថុនា ២០១០)*

អគ្គនាយកដ្ឋានគយបានឱ្យដឹងថានៅខែឧសភា ២០១០នេះគយរកបានចំណូលពន្ធប្រមាណ ២៥០ពាន់លានរៀលគឺប្រមាណ ៥៩លានដុល្លារដែលមានកំណើនប្រមាណ ២២ភាគរយ បើប្រៀបធៀប ទៅនឹងខែមេសា ឆ្នាំ២០០៩។ កាលពីថ្ងៃទី៧មិថុនាឆ្នាំ ២០១០អគ្គនាយកដ្ឋានគយ និងរដ្ឋាករបានរៀបចំកិច្ចប្រជុំសាមញ្ញបូកសរុបលទ្ធផលការងារប្រចាំខែឧសភាឆ្នាំ ២០១០ ក្រោមអធិបតីភាពលោកបណ្ឌិតប៉ែនស៊ីម៉ុនប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកគយកម្ពុជាដោយមានការចូលរួមពីមន្ត្រីថ្នាក់ដឹកនាំគយមកពីគ្រប់ខេត្ត ។លោក បណ្ឌិតប៉ែនស៊ីម៉ុនបានមានប្រសាសន៍ឱ្យដឹង ថានៅខែឧសភាឆ្នាំ ២០១០គយប្រមូលចំណូលបានចំនួន ជាង២៥០ពាន់ លានរៀល ឬប្រមាណជិត ៥៩លានដុល្លារមានចំនួន កើនឡើងប្រមាណ៤៥ពាន់លាន រៀលឬប្រមាណ ២២ភាគរយបើធៀបនឹងខែមេសាឆ្នាំ២០០៩ ។

## ចាប់សាច់មាន់ខូចគុណភាពជាងកន្លះតោនដុតចោល

*(ដើមអំពិល ០៧ មិថុនា ២០១០)*

សាច់មាន់ខូចគុណភាពជាងកន្លះតោនដែលឈ្មួញទុច្ចរិតលួចនាំចូលពីប្រទេសសៀមមកកម្ពុជាតាមច្រកទ្វារព្រំដែនអន្តរជាតិ ប៉ោយប៉ែតត្រូវបានមន្ត្រីពេទ្យសត្វសហការជាមួយនគរបាលក្រុងប៉ោយប៉ែត ស្ទាក់ចាប់យកទៅកំទេចចោល ដែលសរុបជាង ៦០០ គីឡូក្រាម ។

## បណ្តុះបណ្តាលជំនាញកសិកម្មជូនជនរងគ្រោះដោយសារគ្រឿងញៀន

*(វិទ្យុអាស៊ីសេរី ០៧ មិថុនា ២០១០)*

អង្គការក្រៅរដ្ឋាភិបាលមួយបានចុះជួយក្រុមគ្រួសារជនរងគ្រោះដោយសារគ្រឿងញៀន នៅខេត្តកណ្តាលជាង ១០០នាក់ ដោយជួយបង្ហាត់បង្រៀនពួកគាត់ឱ្យចេះដាំដំណាំ និងចិញ្ចឹមសត្វដើម្បីចិញ្ចឹមជីវិត បន្ទាប់ពីបានរងគ្រោះដោយសារគ្រឿងញៀនរួចមក ។